# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

របាយការណ៍ហិរញ្ញវត្ថុ
សង្ខេបចន្លោះពេលសម្រាប់ដំណាច់ការិយបរិច្ឆេទ
3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022
និង
របាយការណ៍របស់សវនករឯករាជ្យ
ស្តីពីការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ
សង្ខេបចន្លោះពេល

# ព័ត៌មានអំពីក្រុមហ៊ុន

| | | |
|---|---|---|
| ក្រុមហ៊ុន | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក | |
| លេខចុះបញ្ជីពាណិជ្ជកម្ម | 00001157 | |
| ទីស្នាក់ការចុះបញ្ជី | អគារលេខ 212 ផ្លូវលេខ 271 សង្កាត់ទួលទំពូង 2<br>ខណ្ឌចំការមន<br>រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា | |
| ភាគទុនិក | Kookmin Bank Co., Ltd<br>ធនាគារគូកមីន កម្ពុជា ភីអិលស៊ី | |
| ក្រុមប្រឹក្សាភិបាល | លោក Kwi Sang Jun | ប្រធានក្រុមប្រឹក្សាភិបាល |
| | លោក Chung Hui Tae | អភិបាល (តែងតាំងនៅថ្ងៃទី23 ខែកុម្ភៈ ឆ្នាំ2022) |
| | លោក អ៊ុំ សមអឿន | អភិបាល (តែងតាំងនៅថ្ងៃទី23 ខែកុម្ភៈ ឆ្នាំ2022) |
| | លោក Choi Dong Hyun | អភិបាល |
| | លោក Lee Kyung Cheon | អភិបាលឯករាជ្យ |
| | លោក Pak Jaehong | អភិបាលឯករាជ្យ |
| | លោក ច័ន្ទ សុផល | អភិបាលឯករាជ្យ |
| | លោក Ji Kyu Jang | អភិបាល (លាលែងនៅថ្ងៃទី18 ខែមករា ឆ្នាំ2022) |
| គណៈកម្មាធិការប្រតិបត្តិ | លោក អ៊ុំ សមអឿន | ប្រធាននាយកប្រតិបត្តិ |
| | លោក គីម ហ្យុនជុង | អនុប្រធាននាយកប្រតិបត្តិ<br>(តែងតាំងនៅថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2022) |
| | លោក អ៊ី ជូហ្វាន់ | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងហានិភ័យ<br>(តែងតាំងនៅថ្ងៃទី14 ខែមករា ឆ្នាំ2022) |
| | លោក វ៉ុន ស៊ូយ៉ុន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកហិរញ្ញវត្ថុ<br>(តែងតាំងនៅថ្ងៃទី14 ខែមករា ឆ្នាំ2022) |
| | លោក គង់ ស៊ាន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកប្រតិបត្តិការ |
| | លោក វី វណ្ណា | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុក<br>គ្រប់គ្រងអាជីវកម្ម |
| | លោក ប៉ែន សុវណ្ណសុខស៊ីថា | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកទីផ្សារ |
| | លោក ហឿន ហុន្នី | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុក<br>ធនធានមនុស្ស |
| | លោក ស៊ឹម សេនាជាតិ | ប្រធាននាយកប្រតិបត្តិ<br>(លាលែងនៅថ្ងៃទី21 ខែមករា ឆ្នាំ2022) |

# ព័ត៌មានអំពីក្រុមហ៊ុន (ត)

គណៈកម្មាធិការប្រតិបត្តិ

| | | |
|---|---|---|
| | លោក អ៊ុំ សូផន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកហិរញ្ញវត្ថុ<br>(ចូលនិវត្តន៍នៅថ្ងៃទី24 ខែមករា ឆ្នាំ2022) |
| | លោក នាង សុខឃីម | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុក<br>គ្រប់គ្រងអាជីវកម្ម<br>(លាលែងនៅថ្ងៃទី28 ខែកុម្ភៈ ឆ្នាំ2022) |
| | លោក សាយ សូនី | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុក<br>គ្រប់គ្រងទីផ្សារ<br>(លាលែងនៅថ្ងៃទី28 ខែមករា ឆ្នាំ2022) |
| | លោក ជួប វាសនា | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុក<br>ធនធានមនុស្ស<br>(លាលែងនៅថ្ងៃទី28 ខែមករា ឆ្នាំ2022) |
| | លោក ជា ហាង | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុក<br>ផែនការយុទ្ធសាស្ត្រ និងអាជីវកម្ម<br>(លាលែងនៅថ្ងៃទី26 ខែមករា ឆ្នាំ2022) |
| សវនករ | ខេភីអឹមជី ខេមបូឌា | |

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក**

# មាតិកា


| | ទំព័រ |
|---|---|
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 1 – 6 |
| របាយការណ៍របស់សវនករឯករាជ្យស្តីពីការត្រួតពិនិត្យលើ<br>របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 7 – 8 |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 9 |
| របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល | 10 |
| របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល | 11 |
| របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល | 12 |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 13 – 53 |

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល (“ក្រុមប្រឹក្សាភិបាល” ឬ“អភិបាល”) នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក (“ក្រុមហ៊ុន”) សូមធ្វើការបង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022។

## ព័ត៌មានអំពីក្រុមហ៊ុន

ក្រុមហ៊ុន គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលបានអាជ្ញាប័ណ្ណ និងចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងចុះបញ្ជីពាណិជ្ជកម្មជាមួយក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រោមបញ្ជីពាណិជ្ជកម្មលេខ 00001157 ចុះថ្ងៃទី19 ខែកញ្ញា ឆ្នាំ2011 និងដែលបានចុះបញ្ជីសារជាថ្មី នាថ្ងៃទី28 ខែមេសា ឆ្នាំ2016។

ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុដល់ក្រុមហ៊ុន ដែលមានសុពលភាពចាប់ពីថ្ងៃទី14 ខែធ្នូ ឆ្នាំ2007។ លើសពីនេះទៅទៀត ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើអាជីវកម្មទទួលប្រាក់បញ្ញើ នៅថ្ងៃទី27 ខែសីហា ឆ្នាំ2010 និងការអនុញ្ញាតឲ្យដំណើរការម៉ាស៊ីនដក-ដាក់ប្រាក់ស្វ័យប្រវត្តិ និងសេវាកម្មបង់ប្រាក់តាមម៉ាស៊ីនឆូតកាតនៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2011។

ទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅអគារលេខ 212 ផ្លូវលេខ 271 សង្កាត់ទូលទំពូង 2 ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## សកម្មភាពអាជីវកម្មចម្បង

ក្រុមហ៊ុនធ្វើប្រតិបត្តិការក្រោមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ដោយផ្តោតជាពិសេសលើការផ្តល់ឥណទាន និងសេវាកម្មហិរញ្ញវត្ថុផ្សេងៗទៀត ដល់ប្រជាពលរដ្ឋទូទៅ ក៏ដូចជាសហគ្រាសធុនតូច និងមធ្យម ព្រមទាំងសកម្មភាពអាជីវកម្មដទៃទៀត ដែលក្រុមប្រឹក្សាភិបាលជឿជាក់ថាគាំទ្រដល់គោលបំណងទាំងនេះ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022 ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## ភាគលាភ

ពុំមានការប្រកាសបែងចែក ឬទូទាត់ភាគលាភនៅក្នុងអំឡុងការិយបរិច្ឆេទនេះទេ ហើយក្រុមប្រឹក្សាភិបាលក៏មិនផ្តល់អនុសាសន៍ឲ្យមានការទូទាត់ភាគលាភ នាកាលបរិច្ឆេទនៃរបាយការណ៍នេះដែរ។

## ដើមទុន

នៅថ្ងៃទី11 ខែមីនា ឆ្នាំ2022 ក្រុមហ៊ុនបានស្នើសុំទៅធនាគារជាតិនៃកម្ពុជាដើម្បីបង្កើនដើមទុនរបស់ខ្លួនពី 300,000,000 ដុល្លារអាមេរិកទៅ 400,000,000 ដុល្លារអាមេរិក តាមរយៈការធ្វើមូលធនកម្មលើប្រាក់ចំណេញរក្សាទុក។ សំណើរនេះត្រូវបានអនុម័តដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី25 ខែមេសា ឆ្នាំ2022។ អនុស្សារណៈ និងលក្ខន្តិកៈក្រុមហ៊ុន ត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនេះ ហើយទទួលបានការយល់ព្រមពីក្រសួងពាណិជ្ជកម្មនៅថ្ងៃទី28 ខែមេសា ឆ្នាំ2022។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តលើទុនបម្រុង និងសំវិធានធននៅក្នុងអំឡុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## ការខាតបង់ដែលបានរំពឹងទុកទៅលើឥណទានផ្តល់ដល់អតិថិជន

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុនត្រូវបានរៀបចំ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានាដើម្បីធ្វើឲ្យប្រាកដថា សកម្មភាពផ្សេងៗត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា ឥណទានអាក្រក់ត្រូវបានលុបចេញពីបញ្ជី ហើយសំវិធានធនត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់សម្រាប់ការខាតបង់ដែលបានរំពឹងទុកទៅលើឥណទាន។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលអាចនឹងបណ្តាលឲ្យចំនួននៃឥណទានអាក្រក់ដែលលុបចេញពីបញ្ជី ឬចំនួននៃសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ថាមានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះឡើយ។

## ទ្រព្យសកម្ម

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាល បានចាត់វិធានការ ដែលមានមូលដ្ឋានសមហេតុផលដើម្បីធ្វើឲ្យប្រាកដថា បណ្តាទ្រព្យសកម្ម (លើកលែងបំណុល) ដែលទំនងជាមិនអាចប្រមូលមកវិញបាននៅក្នុងប្រតិបត្តិការអាជីវកម្ម តាមតម្លៃដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលបានរំពឹងទុកថាអាចប្រមូលបានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវនោះទេ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## វិធីសាស្ត្រនៃការវាយតម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើង បានធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តន៍វិធីសាស្ត្រដែលមានស្រាប់ ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុង របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

## បំណុលយថាភាព និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ៖

- ពុំមានការផ្លាស់ប្តូរលើទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលបានយកមកប្រើប្រាស់សម្រាប់ការធានាចំពោះ បំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមក និង
- ពុំមានបំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុ មកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុនដែលត្រូវបាន ទាមទារឲ្យសង ឬអាចនឹងទាមទារឲ្យសងក្នុងអំឡុងការិយបរិច្ឆេទ បន្ទាប់ពីចុងការិយបរិច្ឆេទនៃរបាយការណ៍នេះ ដែលនឹងបង្កឲ្យមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេល ដែលដល់ថ្ងៃកំណត់ឡើយ។

## ការប្រែប្រួលនៃកាលៈទេសៈ

នាការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលមិនបានរែកញែកនៅ ក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឲ្យមាន តួលេខណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មានភាពមិនត្រឹមត្រូវជាសារវន្ត នោះទេ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុនេះ មិនរងផលប៉ះពាល់ជាសារវន្តពីសកម្មភាពប្រតិបត្តិការ ព្រឹត្តិការណ៍ ឬធាតុណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីចុងការិយបរិច្ឆេទរាយការណ៍មកទល់នឹងកាលបរិច្ឆេទ នៃរបាយការណ៍នេះ ពុំមានសកម្មភាពប្រតិបត្តិការ ព្រឹត្តិការណ៍ ឬធាតុណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិន ប្រក្រតី ដែលអាចបណ្តាលឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរ ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទ រាយការណ៍បច្ចុប្បន្ន ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល នៅក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

| *ឈ្មោះ* | *មុខងារ* |
|---|---|
| លោក Kwi Sang Jun | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Chung Hui Tae | អភិបាល (តែងតាំងនៅថ្ងៃទី23 ខែកុម្ភៈ ឆ្នាំ2022) |
| លោក អ៊ុំ សមអឿន | អភិបាល (តែងតាំងនៅថ្ងៃទី23 ខែកុម្ភៈ ឆ្នាំ2022) |
| លោក Choi Dong Hyun | អភិបាល |
| លោក Lee Kyung Cheon | អភិបាលឯករាជ្យ |
| លោក Pak Jaehong | អភិបាលឯករាជ្យ |
| លោក ច័ន្ទ សុផល | អភិបាលឯករាជ្យ |
| លោក Ji Kyu Jang | អភិបាល (លាលែងនៅថ្ងៃទី18 ខែមករា ឆ្នាំ2022) |

## គណៈគ្រប់គ្រងប្រតិបត្តិ

សមាជិកគណៈគ្រប់គ្រងប្រតិបត្តិនៅក្នុងអំឡុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

| *ឈ្មោះ* | *មុខងារ* |
|---|---|
| លោក អ៊ុំ សមអឿន | ប្រធាននាយកប្រតិបត្តិ |
| លោក គីម ហ្យុនជុង | អនុប្រធាននាយកប្រតិបត្តិ (តែងតាំងនៅថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2022) |
| លោក អ៊ី ជូហ្វាន់ | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងហានិភ័យ (តែងតាំងនៅថ្ងៃទី14 ខែមករា ឆ្នាំ2022) |
| លោក វ៉ុន ស៊ូយ៉ុន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកហិរញ្ញវត្ថុ (តែងតាំងនៅថ្ងៃទី14 ខែមករា ឆ្នាំ2022) |
| លោក គង់ ស៊ាន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកប្រតិបត្តិការ |
| លោក រី វណ្ណា | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងអាជីវកម្ម |
| លោក ប៉ែន សុវណ្ណសុខស៊ីថា | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកទីផ្សារ |
| លោក ហឿន ហុន្នី | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកធនធានមនុស្ស |
| លោក ស៊ឹម សេនាជាតិ | ប្រធាននាយកប្រតិបត្តិ (លាលែងនៅថ្ងៃទី21 ខែមករា ឆ្នាំ2022) |
| លោក អ៊ុំ សូផន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកហិរញ្ញវត្ថុ (ចូលនិវត្តន៍នៅថ្ងៃទី24 ខែមករា ឆ្នាំ2022) |
| លោក នាង សុខឃីម | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងអាជីវកម្ម (លាលែងពីតំណែងថ្ងៃទី28 ខែកុម្ភៈ ឆ្នាំ2022) |
| លោក សាយ សូនី | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងទីផ្សារ (លាលែងនៅថ្ងៃទី28 ខែមករា ឆ្នាំ2022) |
| លោក ជួប វាសនា | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកធនធានមនុស្ស (លាលែងនៅថ្ងៃទី28 ខែមករា ឆ្នាំ2022) |
| លោក ជា ហាង | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកផែនការយុទ្ធសាស្រ្ត និងអាជីវកម្ម (លាលែងនៅថ្ងៃទី26 ខែមករា ឆ្នាំ2022) |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

ពុំមានសមាជិកនៃក្រុមប្រឹក្សាភិបាលណាម្នាក់ មានភាគកម្មដោយផ្ទាល់ក្នុងមូលធនរបស់ក្រុមហ៊ុនឡើយ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានកិច្ចព្រមព្រៀងណាមួយដែលមានក្រុមហ៊ុនជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះបានផ្តល់លទ្ធភាពដល់សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ ឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬរបស់សាជីវកម្មដទៃឡើយ។

ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬជាមួយនឹងក្រុមហ៊ុនដែលមានអភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនណាមួយដែលអភិបាលនោះ មានភាគកម្មផ្នែកហិរញ្ញវត្ថុជាសារវន្តនោះឡើយ លើកលែងតែអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

ក្រុមប្រឹក្សាភិបាល មានភារៈទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែមីនា ឆ្នាំ2022 និងសម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ ដូចបានបង្ហាញនៅ ទំព័រទី 9 ដល់ទី 53 ត្រូវបានរៀបចំឡើងជាសារវន្ត ដោយអនុលោមទៅតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល* ("ស.គ.អ.ក 34")។ ក្រុមប្រឹក្សាភិបាល ត្រួតពិនិត្យលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដែលធ្វើឡើងដោយគណៈគ្រប់គ្រង ដែលត្រូវបានតម្រូវឲ្យ៖

- អនុម័តនូវគោលនយោបាយគណនេយ្យសមស្របនានា ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានយ៉ាងសមហេតុផល និងដោយភាពប្រុងប្រយ័ត្ន ហើយត្រូវអនុវត្តគោលនយោបាយទាំងនេះប្រកបដោយសង្គតិភាព។
- អនុលោមតាមលក្ខខណ្ឌតម្រូវនៃការលាតត្រដាងព័ត៌មាន និងការណែនាំផ្សេងៗ ដែលចេញផ្សាយដោយ ស.គ.អ.ក 34 ឬប្រសិនបើមានវៀចចាកពីការបង្ហាញព័ត៌មានដ៏សមស្រប គឺត្រូវធ្វើឲ្យប្រាកដថា ការវៀចចាកទាំងនេះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឲ្យបានសមស្របក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។
- រក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លុះត្រាតែវាមានភាពមិនសមរម្យក្នុងការសន្មតថា ក្រុមហ៊ុននឹងអាចបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគតបាន។
- បង្កើតគោលការណ៍ជារួមសម្រាប់ក្រុមហ៊ុន អនុម័តរាល់សេចក្តីសម្រេច និងសកម្មភាពទាំងឡាយធ្វើឡើងដោយគណៈគ្រប់គ្រង ដែលមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការអាជីវកម្ម និងលទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ហើយត្រូវធានាថាគោលនយោបាយ និងសេចក្តីសម្រេចទាំងនោះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)

គណៈគ្រប់គ្រង មានភារៈទទួលខុសត្រូវក្នុងការរក្សាទុកបញ្ជីគណនេយ្យឲ្យបានត្រឹមត្រូវ (រួមទាំងភាពច្បាស់លាស់នៃបញ្ជីនេះ នៅគ្រប់ពេលវេលា) ដែលបង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងត្រូវធានាថា បញ្ជីគណនេយ្យបានអនុលោមតាមប្រព័ន្ធគណនេយ្យដែលបានចុះបញ្ជី។ គណៈគ្រប់គ្រងក៏មានភារៈទទួលខុសត្រូវផងដែរចំពោះការការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងចាត់វិធានការសមស្របនានា ដើម្បីទប់ស្កាត់ និងស្វែងរកការក្លែងបន្លំ និងភាពមិនប្រក្រតី។

ក្រុមប្រឹក្សាភិបាលបានអះអាងថា គណៈគ្រប់គ្រងបានអនុវត្តតាមលក្ខខណ្ឌតម្រូវខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

យើងខ្ញុំ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល រួមទាំងកំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ ថាត្រូវបានរៀបចំឡើង គ្រប់ទិដ្ឋភាពជាសារវន្ត ដោយអនុលោមទៅតាម ស.គ.អ.ក 34។

*ចុះហត្ថលេខាដោយយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល៖*

ព្រះរាជាណាចក្រកម្ពុជា
គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក
ហៅកាត់ថា ប្រាសាក់មីអេហ្វអាយ ម.ក
PRASAC MICROFINANCE INSTITUTION PLC.
"PRASAC MFI PLC."
ការិយាល័យកណ្តាលរាជធានីភ្នំពេញ

លោក Kwi Sang Jun
*ប្រធានក្រុមប្រឹក្សាភិបាល*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី12 ខែឧសភា ឆ្នាំ2022

KPMG Cambodia Ltd
GIA Tower, Sopheak Mongkul Street, Phum 14
Sangkat Tonle Bassac, Khan Chamkar Mon
Phnom Penh, Cambodia
+ 855 (17) 666 537 / + 855 (81) 533 999 | kpmg.com.kh

# របាយការណ៍របស់សវនករឯករាជ្យស្តីពីការត្រួតពិនិត្យលើ របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## ជូនចំពោះភាគទុនិករបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

### *សេចក្តីផ្តើម*

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022 របស់គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក ដែលបានបង្ហាញនៅទំព័រទី 9 ដល់ទី 53 (ហៅកាត់ថា "ក្រុមហ៊ុន") ជារួមហៅកាត់ថា ("របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល") ដែលរួមមាន៖

- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល នាថ្ងៃទី31 ខែមីនា ឆ្នាំ2022
- របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022
- របាយការណ៍ បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022
- របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022 និង
- កំណត់សម្គាល់ពន្យល់ផ្សេងៗទៀត។

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 "*របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*"។ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺផ្តល់ការសន្និដ្ឋានលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលដោយផ្អែកលើការធ្វើការត្រួតពិនិត្យរបស់យើងខ្ញុំ។

KPMG Cambodia Ltd., a Cambodian single member private limited company and a member firm of the KPMG global organization of independent member firms affiliated with KPMG International Limited, a private English company limited by guarantee. All rights reserved.

KPMG

## *វិសាលភាពនៃការត្រួតពិនិត្យ*

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយអនុលោមទៅតាមស្តង់ដាអន្តរជាតិនៃកម្ពុជាសម្រាប់កិច្ចការងារត្រួតពិនិត្យលេខ 2410 ស្តីពី *"ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុចន្លោះពេល ដែលអនុវត្តដោយសវនករឯករាជ្យរបស់ក្រុមហ៊ុន"*។ ការត្រួតពិនិត្យ លើព័ត៌មានហិរញ្ញវត្ថុចន្លោះពេល រួមមានការសាកសួរព័ត៌មាន ជាពិសេសសាកសួរបុគ្គលដែល មានភារៈទទួលខុសត្រូវលើបញ្ហាគណនេយ្យ និងហិរញ្ញវត្ថុ ហើយធ្វើការវិភាគ និងអនុវត្តនូវនីតិវិធីត្រួតពិនិត្យផ្សេងៗ។ ការត្រួតពិនិត្យ មានវិសាលភាពតូចជាងការធ្វើសវនកម្ម ដែលអនុលោមតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា ហេតុដូច្នេះ ការត្រួតពិនិត្យមិនអាចឲ្យយើងខ្ញុំផ្តល់នូវអំណះអំណាងថា យើងខ្ញុំបានដឹងនូវរាល់បញ្ហាជាសារវន្តទាំងឡាយ ដែលអាចនឹងត្រូវបានរកឃើញក្នុងពេលធ្វើសវនកម្មនោះឡើយ។ ហេតុដូច្នេះយើងខ្ញុំ មិនបញ្ចេញមតិសវនកម្មនោះទេ។

## *សេចក្តីសន្និដ្ឋាន*

ផ្អែកលើការត្រួតពិនិត្យរបស់យើងខ្ញុំ ពុំមានបញ្ហាណាមួយដែលបានទាញចំណាប់អារម្មណ៍យើងខ្ញុំ ដែលបណ្តាលឲ្យយើងខ្ញុំជឿថា របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនត្រូវបានរៀបចំជាសារវន្ត ស្របតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 *(របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល)* នោះឡើយ។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា**

ព្រះរាជាណាចក្រកម្ពុជា
ខេ ភី អឹម ជី ខេមបូឌា
KPMG CAMBODIA LTD.
ទីស្នាក់ការរាជធានីភ្នំពេញ

**ទេ ហ៊ុយ**

*Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី 12 ខែឧសភា ឆ្នាំ 2022

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## នាថ្ងៃទី31 ខែមីនា ឆ្នាំ2022

| | កំណត់សម្គាល់ | ថ្ងៃទី31 ខែមីនា ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 6 | 173,293,768 | 701,839,760 | 222,365,399 | 905,916,636 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 7 | 383,051,987 | 1,551,360,547 | 368,419,366 | 1,500,940,497 |
| សមតុល្យនៅធនាគារផ្សេងៗ | 8 | 3,258,969 | 13,198,824 | 2,308,097 | 9,403,187 |
| ឥណទានផ្តល់ដល់អតិថិជន | 9 | 3,948,537,478 | 15,991,576,786 | 3,691,567,993 | 15,039,448,003 |
| ទ្រព្យសកម្មផ្សេងៗ | 10 | 2,083,617 | 8,438,649 | 1,815,969 | 7,398,258 |
| ទ្រព្យ និងបរិក្ខារ | 11 | 4,844,384 | 19,619,756 | 4,861,518 | 19,805,825 |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | 12 | 16,083,574 | 65,138,475 | 16,097,643 | 65,581,798 |
| ទ្រព្យសកម្មអរូបី | 13 | 1,281,321 | 5,189,350 | 1,354,529 | 5,518,351 |
| ពន្ធពន្យារសុទ្ធជាទ្រព្យសកម្ម | 20(គ) | 12,798,058 | 51,832,135 | 11,727,635 | 47,778,385 |
| **ទ្រព្យសកម្មសរុប** | | **4,545,233,156** | **18,408,194,282** | **4,320,518,149** | **17,601,790,940** |
| **បំណុល និងមូលធនម្ចាស់ភាគហ៊ុន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើពីធនាគារនានា និង គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | 14 | 74,684,584 | 302,472,565 | 81,881,578 | 333,585,549 |
| ប្រាក់បញ្ញើរបស់អតិថិជន | 15 | 2,655,082,438 | 10,753,083,874 | 2,533,330,855 | 10,320,789,903 |
| ប្រាក់កម្ចី | 16 | 902,805,735 | 3,656,363,227 | 829,821,864 | 3,380,694,274 |
| មូលបត្របំណុលត្រូវសង | 17 | 32,239,835 | 130,571,332 | 31,342,099 | 127,687,711 |
| អនុបំណុល | 18 | 106,144,131 | 429,883,731 | 105,191,790 | 428,551,352 |
| បំណុលភតិសន្យា | 19 | 15,613,630 | 63,235,202 | 15,591,438 | 63,519,518 |
| បំណុលពន្ធលើប្រាក់ចំណេញ | 20(ខ) | 11,078,588 | 44,868,281 | 34,153,679 | 139,142,088 |
| សំវិធានធនលើអត្ថប្រយោជន៍ និយោជិត | 21 | 1,375,762 | 5,571,836 | 237,906 | 969,229 |
| បំណុលផ្សេងៗ | 22 | 22,482,090 | 91,052,465 | 14,627,852 | 59,593,871 |
| **បំណុលសរុប** | | **3,821,506,793** | **15,477,102,513** | **3,646,179,061** | **14,854,533,495** |
| **មូលធនម្ចាស់ភាគហ៊ុន** | | | | | |
| ដើមទុន | 23(ក) | 300,000,000 | 1,200,000,000 | 300,000,000 | 1,200,000,000 |
| ប្រាក់ចំណេញរក្សាទុក | | 396,523,487 | 1,621,136,409 | 349,600,939 | 1,430,490,098 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 23(ខ) | 27,202,876 | 110,550,405 | 24,738,149 | 100,536,219 |
| ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | - | (595,045) | - | 16,231,128 |
| **មូលធនម្ចាស់ភាគហ៊ុនសរុប** | | **723,726,363** | **2,931,091,769** | **674,339,088** | **2,747,257,445** |
| **បំណុល និងមូលធនម្ចាស់ភាគហ៊ុនសរុប** | | **4,545,233,156** | **18,408,194,282** | **4,320,518,149** | **17,601,790,940** |

កំណត់សម្គាល់ដែលភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022

| | កំណត់សម្គាល់ | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022 ដុល្លារអាមេរិក | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022 សមមូលពាន់រៀល (កំណត់សម្គាល់ 4) | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021 ដុល្លារអាមេរិក | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021 សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
|---|---|---|---|---|---|
| ចំណូលការប្រាក់ | 24 | 140,746,793 | 571,854,220 | 118,818,341 | 482,283,647 |
| ចំណាយការប្រាក់ | 25 | (56,971,835) | (231,476,566) | (50,217,821) | (203,834,136) |
| **ចំណូលការប្រាក់សុទ្ធ** | | 83,774,958 | 340,377,654 | 68,600,520 | 278,449,511 |
| ចំណូលកម្រៃជើងសា | 26 | 2,547,402 | 10,350,094 | 2,173,850 | 8,823,658 |
| ចំណាយកម្រៃជើងសា | 26 | (23,112) | (93,904) | (21,075) | (85,544) |
| **ចំណូលសុទ្ធពីកម្រៃជើងសា និងប្រាក់កម្រៃ** | 26 | 2,524,290 | 10,256,190 | 2,152,775 | 8,738,114 |
| ចំណូលផ្សេងៗ | 27 | 2,820,292 | 11,458,846 | 2,877,695 | 11,680,565 |
| ចំណូលវិភាគទាន | | 134,492 | 546,441 | 365,210 | 1,482,388 |
| ចំណេញសុទ្ធពីការប្តូររូបិយប័ណ្ណ | | 380,696 | 1,546,768 | 641,598 | 2,604,247 |
| **ចំណូលផ្សេងៗសរុប** | | 3,335,480 | 13,552,055 | 3,884,503 | 15,767,200 |
| **ចំណូលសរុបពីការប្រាក់ កម្រៃជើងសា និងចំណូលផ្សេងៗ** | | 89,634,728 | 364,185,899 | 74,637,798 | 302,954,825 |
| ចំណាយលើបុគ្គលិក | 28 | (23,721,483) | (96,380,385) | (20,385,032) | (82,742,845) |
| សំវិធានធនលើការខាតបង់នៃឱនភាពនៃតម្លៃ | 9 | 1,005,951 | 4,087,179 | (4,252,318) | (17,260,159) |
| ចំណាយទូទៅ និងរដ្ឋបាល | 29 | (3,703,743) | (15,048,308) | (3,641,347) | (14,780,228) |
| រំលស់ | 30 | (1,634,026) | (6,639,048) | (1,611,500) | (6,541,079) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | 61,581,427 | 250,205,337 | 44,747,601 | 181,630,514 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 20(ក) | (12,194,152) | (49,544,840) | (8,783,546) | (35,652,414) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | 49,387,275 | 200,660,497 | 35,964,055 | 145,978,100 |
| *ខាតលម្អិតផ្សេងៗ៖* | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (16,826,173) | - | (503,498) |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | | 49,387,275 | 183,834,324 | 35,964,055 | 145,474,602 |

កំណត់សម្គាល់ដែលភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022

| | ដើមទុន | | ប្រាក់ចំណេញរក្សាទុក | | ទុនបម្រុង | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| សមតុល្យថ្ងៃទី1 ខែមករា ឆ្នាំ2022 | 300,000,000 | 1,200,000,000 | 349,600,939 | 1,430,490,098 | - | - | 24,738,149 | 100,536,219 | - | 16,231,128 | 674,339,088 | 2,747,257,445 |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 49,387,275 | 200,660,497 | - | - | - | - | - | - | 49,387,275 | 200,660,497 |
| ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | (2,464,727) | (10,014,186) | - | - | 2,464,727 | 10,014,186 | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | | - | (16,826,173) | - | (16,826,173) |
| **សមតុល្យថ្ងៃទី31 ខែមីនា ឆ្នាំ2022** | 300,000,000 | 1,200,000,000 | 396,523,487 | 1,621,136,409 | - | - | 27,202,876 | 110,550,405 | - | (595,045) | 723,726,363 | 2,931,091,769 |
| សមតុល្យថ្ងៃទី1 ខែមករា ឆ្នាំ2021 | 230,000,000 | 920,000,000 | 285,224,840 | 1,163,897,093 | 3,151,952 | 12,773,175 | 461,332 | 1,778,127 | - | 251,817 | 518,838,124 | 2,098,700,212 |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 35,964,055 | 145,978,100 | - | - | - | - | - | - | 35,964,055 | 145,978,100 |
| ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | (662,073) | (2,687,354) | - | - | 662,073 | 2,687,354 | - | - | - | - |
| ការផ្ទេរទៅទុនបម្រុង | - | - | (14,655) | (59,485) | 14,655 | 59,485 | - | - | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | (503,498) | - | (503,498) |
| **សមតុល្យថ្ងៃទី31 ខែមីនា ឆ្នាំ2021** | 230,000,000 | 920,000,000 | 320,512,167 | 1,307,128,354 | 3,166,607 | 12,832,660 | 1,123,405 | 4,465,481 | - | (251,681) | 554,802,179 | 2,244,174,814 |

កំណត់សម្គាល់ដែលភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022

| | កំណត់សម្គាល់ | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ ថ្ងៃទី31 ខែមីនា ឆ្នាំ2022 | | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ ថ្ងៃទី31 ខែមីនា ឆ្នាំ2021 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ** | 31 | (114,657,601) | (465,853,833) | (74,503,061) | (302,407,923) |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | | (502,032) | (2,039,756) | (409,461) | (1,662,002) |
| ការទិញទ្រព្យសកម្មអរូបី | | - | - | (43,735) | (177,520) |
| ការវិនិយោគលើវិញ្ញាបនប័ត្រប្រាក់បញ្ញើដែលអាចចរចាបាន | | (523,421) | (2,126,660) | - | - |
| សាច់ប្រាក់បានពីការលក់ទ្រព្យ និងបរិក្ខារ | | 899 | 3,653 | 62,059 | 251,897 |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | (1,024,554) | (4,162,763) | (391,137) | (1,587,625) |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | | 151,866,049 | 617,031,757 | 60,244,129 | 244,530,920 |
| ការទូទាត់ប្រាក់កម្ចី | | (79,126,963) | (321,492,851) | (47,940,373) | (194,589,974) |
| ការទូទាត់អនុបំណុល | | (685,900) | (2,786,812) | (2,666,667) | (10,824,001) |
| ការទូទាត់បំណុលភតិសន្យា | | (1,006,112) | (4,087,833) | (962,485) | (3,906,727) |
| **សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | | 71,047,074 | 288,664,261 | 8,674,604 | 35,210,218 |
| **ការថយចុះសុទ្ធ នៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | (44,635,081) | (181,352,335) | (66,219,594) | (268,785,330) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ | | 364,927,185 | 1,486,713,352 | 417,065,787 | 1,687,031,108 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (8,177,997) | - | 927,071 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | 6 | 320,292,104 | 1,297,183,020 | 350,846,193 | 1,419,172,849 |

កំណត់សម្គាល់ដែលភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយ និងត្រូវអានភ្ជាប់ជាមួយរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## 1. ព័ត៌មានទូទៅ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលបានអាជ្ញាប័ណ្ណ និងចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុន ត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រោមបញ្ជីពាណិជ្ជកម្មលេខ 00001157 នៅថ្ងៃទី19 ខែកញ្ញា ឆ្នាំ2011។ ក្រុមហ៊ុនបានចុះបញ្ជីសារជាថ្មី នៅថ្ងៃទី28 ខែមេសា ឆ្នាំ2016។

ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុដល់ក្រុមហ៊ុន ដែលមានសុពលភាពចាប់ពីថ្ងៃទី14 ខែធ្នូ ឆ្នាំ2007។ លើសពីនេះទៅទៀត ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើអាជីវកម្មទទួលប្រាក់បញ្ញើ នៅថ្ងៃទី27 ខែសីហា ឆ្នាំ2010 និងការអនុញ្ញាតឲ្យដំណើរការម៉ាស៊ីនដក-ដាក់ប្រាក់ស្វ័យប្រវត្តិ និងសេវាកម្មបង់ប្រាក់តាមម៉ាស៊ីនឆូតកាតនៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2011។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មហិរញ្ញវត្ថុដល់សហគមន៍ជនបទ និងសហគ្រាសខ្នាតតូចក្នុងប្រទេសកម្ពុជា តាមរយៈការិយាល័យកណ្តាលរបស់ក្រុមហ៊ុន នៅក្នុងរាជធានីភ្នំពេញ និងសាខាជាច្រើនទៀតនៅក្នុងរាជធានីភ្នំពេញ និងខេត្តនានាក្នុងព្រះរាជាណាចក្រកម្ពុជា។

ស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅអគារលេខ 212 ផ្លូវលេខ 271 សង្កាត់ទូលទំពូង 2 ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមថ្ងៃទី31 ខែមីនា ឆ្នាំ2022 ក្រុមហ៊ុនមានបុគ្គលិកចំនួន 9,383 នាក់(ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ ចំនួន 9,330នាក់)។

## 2. មូលដ្ឋានទូទៅនៃការរៀបចំ

### (ក) របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានរៀបចំឡើង ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ("ស.គ.អ.ក") 34 *"របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល"*។ របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនបានរួមបញ្ចូលនូវរាល់ព័ត៌មានទាំងស្រុងរបស់របាយការណ៍ហិរញ្ញវត្ថុ តាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជានោះទេ។ យ៉ាងណាមិញ កំណត់សម្គាល់ពន្យល់បន្ថែមដែលបានជ្រើសរើស ត្រូវបានដាក់បញ្ចូលដើម្បីពន្យល់ពីព្រឹត្តិការណ៍ និងប្រតិបត្តិការទាំងឡាយដែលមានលក្ខណៈជាសារវន្ត ក្នុងការស្វែងយល់ពីបម្រែបម្រួលនៃស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលរបស់ក្រុមហ៊ុន ចាប់តាំងពីរបាយការណ៍ហិរញ្ញវត្ថុចុងក្រោយនាកាលបរិច្ឆេទ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021។

## 2. មូលដ្ឋានទូទៅនៃការរៀបចំ (ត)

### (ក) របាយការណ៍អនុលោមភាព (ត)

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានអនុម័ត និងផ្តល់សិទ្ធិបោះផ្សាយដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី12 ខែឧសភា ឆ្នាំ2022។

### (ខ) រូបិយប័ណ្ណមុខងារ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺប្រាក់រៀល។ ដោយសារក្រុមហ៊ុន ធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួន ផ្អែកលើមូលដ្ឋានប្រាក់ដុល្លារអាមេរិក អ្នកគ្រប់គ្រងក៏បានកំណត់ថាប្រាក់ដុល្លារអាមេរិក ជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន ព្រោះវាបានឆ្លុះបញ្ចាំងពីធាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន។

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ តួលេខទាំងអស់ ត្រូវបានកាត់ខ្ទង់ចំនួនមួយដុល្លារអាមេរិក ដែលជិតបំផុត លុះត្រាតែមានការបង្ហាញផ្សេងពីនេះ។

### (គ) ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ក្រុមហ៊ុនធ្វើការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធនឹងអនាគត។ តាមនិយមន័យ ការប៉ាន់ស្មានគណនេយ្យនឹងកម្រស្មើនឹងលទ្ធផលជាក់ស្តែងដែលពាក់ព័ន្ធ។ ដើម្បីលើកកម្ពស់ខ្លឹមសារព័ត៌មាននៃការប៉ាន់ស្មាន អថេរសំខាន់ៗមួយចំនួន ដែលត្រូវបានគេរំពឹងថានឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធផល និងស្ថានភាពហិរញ្ញវត្ថុចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានធ្វើតេស្តលើរំញោចនៃការផ្លាស់ប្តូរនៃប៉ារ៉ាម៉ែត្រ ដែលជាមូលដ្ឋានក្នុងការប៉ាន់ស្មាន។ ការប៉ាន់ស្មាន និងការសន្មតដែលមានហានិភ័យធ្ងន់ធ្ងរ ដែលអាចបណ្តាលឲ្យមានការកែតម្រូវជាសារវន្តលើតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុបន្ទាប់ ត្រូវបានព័ណ៌នាដូចខាងក្រោម៖

#### *(i) ការវិនិច្ឆ័យ*

ព័ត៌មានអំពីការវិនិច្ឆ័យ ដែលបានធ្វើឡើងក្នុងការអនុវត្តគោលនយោបាយគណនេយ្យដែលមានឥទ្ធិពលជាសារវន្ត លើចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានបញ្ចូលក្នុងកំណត់សម្គាល់ដូចខាងក្រោម។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022**

## 2. មូលដ្ឋានទូទៅនៃការរៀបចំ (ត)

### (គ) ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ (ត)

*(i) ការវិនិច្ឆ័យ (ត)*

- ការចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ៖ ការវាយតម្លៃម៉ូឌែលអាជីវកម្មដែលទ្រព្យទាំងនោះត្រូវបានកាន់កាប់ និងការវាយតម្លៃថាតើលក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាការទូទាត់តែប្រាក់ដើម និងការប្រាក់ ("SPPI") លើចំនួនប្រាក់ដើមដែលនៅសល់។
- ការកើនឡើងជាសារវន្តចំពោះហានិភ័យឥណទាន៖ ការបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ថាតើហានិភ័យឥណទានលើទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់ដំបូងដែរ ឬទេ ការកំណត់វិធីសាស្ត្រសម្រាប់ការដាក់បញ្ចូលព័ត៌មានរំពឹងទុកនាពេលអនាគត ទៅក្នុងការវាស់វែងលើ ការខាតបង់រំពឹងទុកលើឥណទាន ("ECL") និងការជ្រើសរើស និងការអនុម័តលើម៉ូឌែលសម្រាប់ការវាស់វែង ECL។

*(ii) ភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន*

- ឱនភាពនៃតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ៖ កំណត់ការបញ្ចូលធាតុចូលទៅក្នុងគំរូនៃការវាស់វែង ECL រួមទាំងការបញ្ចូលព័ត៌មានរំពឹងទុកនាពេលអនាគត។
- ការកំណត់លើតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុជាមួយធាតុចូលមិនអាចអង្កេតបានជាសារវន្ត។
- ការទទួលស្គាល់ និងការវាស់វែងយថាភាព៖ ការសន្មតសំខាន់ៗលើភវនីយភាព និងទំហំនៃលំហូរចេញនូវធនធាន។
- ឱនភាពនៃតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ៖ ការសន្មតសំខាន់ៗ ដែលត្រូវបានយកមកប្រើប្រាស់ក្នុងការប៉ាន់ស្មានលើលំហូរទឹកប្រាក់ដែលអាចប្រមូលមកវិញបាន។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022**

## 2. មូលដ្ឋានទូទៅនៃការរៀបចំ (ត)

### (គ) ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ (ត)

*(ii) ភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន (ត)*

**វីរុសកូវីដ និងផលប៉ះពាល់លើ ECL**

ECL ត្រូវបានប៉ាន់ប្រមាណដោយផ្អែកទៅលើលក្ខខណ្ឌសេដ្ឋកិច្ចមួយចំនួនដែលបានព្យាករណ៍ នាកាលបរិច្ឆេទរាយការណ៍។ ការផ្ទុះឡើងនៃវីរុសណូវែលកូរ៉ូណា ("ជំងឺកូវីដ-19") បានរាតត្បាតទូទាំងសកលលោក (រួមបញ្ចូលទាំងប្រទេសចិនដីគោក ប្រទេសកម្ពុជា និងបណ្តាប្រទេសផ្សេងៗទៀត) ដែលបានធ្វើឲ្យមានការរាំងស្ទះលើសកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ច។ ផលប៉ះពាល់ទៅលើផលិតផលក្នុងស្រុកសរុប (GDP) និងសូចនាករសំខាន់ៗផ្សេងទៀត នឹងត្រូវយកមកពិចារណា សម្រាប់ការកំណត់នូវភាពធ្ងន់ធ្ងរ និងភវនីយភាពនៃការធ្លាក់ចុះនៃសេណារីយ៉ូសេដ្ឋកិច្ចនានា ដែលត្រូវបានយកមកប្រើក្នុងការប៉ានស្មាន ECL។ ការប៉ានស្មានរបស់អ្នកគ្រប់គ្រង ត្រូវបានកំណត់ដោយផ្អែកទៅលើសេណារីយ៉ូដែលអាចកើតឡើង នាពេលអនាគត ដោយគិតពីស្ថានភាពជាក់ស្តែង កាលៈទេសៈ និងការព្យាករណ៍នៃស្ថានភាពសេដ្ឋកិច្ច នាពេលអនាគត និងព័ត៌មានគាំទ្រដែលអាចប្រើប្រាស់បាន នាកាលបរិច្ឆេទរាយការណ៍នេះ។

ការគណនា ECL នៅស្ថានភាពបច្ចុប្បន្នអាចមានភាពមិនប្រាកដប្រជាជាសារវន្ត។ អ្នកគ្រប់គ្រងបានធ្វើការព្យាករណ៍ដ៏ប្រសើរបំផុត លើផលប៉ះពាល់របស់វីរុសកូរ៉ូណាមកលើក្រុមហ៊ុន យ៉ាងណាមិញ ការព្យាករណ៍នេះអាចនឹងប្រែប្រួលជាសារវន្តនៅពេលមានព្រឹត្តិការណ៍ថ្មីៗកើតឡើងជាក់ស្តែង។ ជាលទ្ធផល តួលេខនេះ មិនគួរត្រូវបានយកជាការណែនាំជាក់លាក់ ឬជាការព្យាករណ៍នៃផលប៉ះពាល់ហិរញ្ញវត្ថុចុងក្រោយ ដែលបានរំពឹងទុកនោះទេ។ ក្នុងករណីដែលផលប៉ះពាល់នោះមានសភាពកាន់តែធ្ងន់ធ្ងរ និងមានរយៈពេលយូរជាងការរំពឹងទុក នោះផលប៉ះពាល់ទន្ទឹមគ្នានឹងកើតមានឡើងចំពោះ ECL មកលើស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

ចំនួននៃឥណទានរៀបចំឡើងវិញ បានកើនឡើងជាលំដាប់ ដោយសារតែផលប៉ះពាល់ពីជំងឺរាតត្បាតកូវីដ-19។ នៅថ្ងៃទី28 ខែធ្នូ ឆ្នាំ 2021 ធនាគារជាតិនៃកម្ពុជាបានចេញសារាចរណែនាំលេខ ធ7.021.2314.ឆ.ត ស្តីពីកាតព្វកិច្ចធ្វើចំណាត់ថ្នាក់ និងសំវិធានធន ចំពោះឥណទានរៀបចំឡើងវិញ ក្នុងគោលបំណងកាត់បន្ថយនូវហានិភ័យឥណទាន សំដៅរក្សាស្ថេរភាពហិរញ្ញវត្ថុ និងគាំទ្រដល់ការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ច។ ឥណទានរៀបចំឡើងវិញទាំងឡាយគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ត្រូវធ្វើចំណាត់ថ្នាក់ និងសំវិធានធនឡើងវិញ ដោយផ្អែកទៅលើសារាចរណែនាំនេះ។ ចំពោះឥណទានដែលស្ថិតក្នុងរយៈពេលវាយតម្លៃ ត្រូវរក្សាចំណាត់ថ្នាក់ដូចនៅមុនពេលដែលមានការរៀបចំឡើងវិញ។

ក្រុមហ៊ុន បានពិនិត្យសារាចរនេះ និងមានទស្សនៈថា ការវាយតម្លៃទៅលើហានិភ័យឥណទានរបស់ក្រុមហ៊ុនដែលមានស្រាប់ មានភាពសមស្របទៅតាមតម្រូវការដែលមានចែងនៅក្នុងសារាចរនេះ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗ ដែលត្រូវបានយកមកអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល គឺដូចគ្នាទៅនឹងគោលនយោបាយដែលបានអនុវត្តនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2021។

## 4. ការប្តូររូបិយប័ណ្ណប្រាក់ដុល្លារអាមេរិកទៅប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលត្រូវជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិក ទៅជាប្រាក់រៀលខ្មែរ បានបំពេញតាមលក្ខខណ្ឌតម្រូវនៃការបង្ហាញពត៌មានដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ហើយការប្តូររូបិយប័ណ្ណនេះធ្វើឡើងដោយអនុលោមទៅតាម ស.គ.អ.ក 21–*ឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូររូបិយប័ណ្ណបរទេស*។

ទ្រព្យសកម្ម និងបំណុលត្រូវបានប្តូរតាមអត្រានាកាលបរិច្ឆេទរាយការណ៍ ហើយដើមទុន និងគណនីមូលធនផ្សេងៗត្រូវបានប្តូរតាមអត្រាប្រវត្តិសាស្រ្ត។ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ និងរបាយការណ៍លំហូរទឹកប្រាក់ ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើប្រាស់អត្រាមធ្យម នៅក្នុងការិយបរិច្ឆេទដែលអត្រានេះត្រូវបានចាត់ទុកថាមានកម្រិតប្រហាក់ប្រហែលទៅនឹងអត្រាប្តូររូបិយប័ណ្ណ នាថ្ងៃប្រតិបត្តិការដោយសារតែអត្រាប្តូររូបិយប័ណ្ណ មិនមានការប្រែប្រួលជាសារវន្តនៅក្នុងការិយបរិច្ឆេទ។ ភាពខុសគ្នាដែលកើតឡើងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជា "លម្អៀងពីការប្តូររូបិយប័ណ្ណ" នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

ក្រុមហ៊ុនប្រើប្រាស់អត្រាប្តូរប្រាក់ដូចខាងក្រោម៖

| | | **អត្រានាកាល បរិច្ឆេទរាយការណ៍** | **អត្រាមធ្យម ការិយបរិច្ឆេទ 3ខែ** |
|---|---|---|---|
| ថ្ងៃទី31 ខែមីនា ឆ្នាំ2022 | 1 ដុល្លារអាមេរិក = | 4,050រៀល | 4.063រៀល |
| ថ្ងៃទី31 ខែមីនា ឆ្នាំ2021 | 1 ដុល្លារអាមេរិក = | 4,045រៀល | 4,059រៀល |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | 1 ដុល្លារអាមេរិក = | 4,074រៀល | គ្មាន |

តួលេខជាប្រាក់រៀលនេះ គឺសម្រាប់ជាការបង្ហាញតែប៉ុណ្ណោះ ហើយមិនត្រូវបានយកមកបកស្រាយថា តួលេខប្រាក់ដុល្លារអាមេរិកនេះត្រូវបានប្តូរទៅជាប្រាក់រៀល ឬគួរត្រូវបានប្តូរជាប្រាក់រៀល ឬនឹងត្រូវបានប្តូរជាប្រាក់រៀល នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022

### 5. បម្រែបម្រួលតាមរដូវកាលនៃប្រតិបត្តិការអាជីវកម្ម

សកម្មភាពចម្បងរបស់ក្រុមហ៊ុន ជាទូទៅពាក់ព័ន្ធនឹងការផ្តល់សេវាឥណទាន និងសេវាកម្មហិរញ្ញវត្ថុផ្សេងៗ ដល់ប្រជាពលរដ្ឋ សហគ្រាសធនតូច និងមធ្យម ព្រមទាំងចូលរួមក្នុងរាល់សកម្មភាពផ្សេងៗទៀត ដែលគាំទ្រដល់កម្មវត្ថុទាំងនេះ។ ពុំមានបច្ច័យដែលនាំឲ្យមានបម្រែបម្រួលតាមរដូវកាលនៃប្រតិបត្តិការអាជីវកម្ម ដែលមានលក្ខណៈជាសារវន្ត ដែលពាក់ព័ន្ធនឹងសកម្មភាពធុរកិច្ចទាំងនេះទេ។

### 6. សាច់ប្រាក់ក្នុងដៃ

| | ថ្ងៃទី31 ខែមីនា ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| ទីស្នាក់ការកណ្តាល | 37,545,859 | 152,060,729 | 37,795,735 | 153,979,824 |
| សាខានានា | 135,747,909 | 549,779,031 | 184,569,664 | 751,936,812 |
| | 173,293,768 | 701,839,760 | 222,365,399 | 905,916,636 |

សម្រាប់គោលបំណងនៃការរៀបចំរបាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានដូចខាងក្រោម៖

| | ថ្ងៃទី31 ខែមីនា ឆ្នាំ2022 | | ថ្ងៃទី31 ខែមីនា ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| សាច់ប្រាក់ក្នុងដៃ | 173,293,768 | 701,839,760 | 189,528,409 | 766,642,414 |
| *សមតុល្យនៅធនាគារជាតិនៃកម្ពុជ* | | | | |
| គណនីចរន្ត | 103,706,447 | 420,011,110 | 78,456,720 | 317,357,432 |
| គណនីមានកាលកំណត់ (កាលវសានដំបូងរហូតដល់ 3ខែ) | 40,000,000 | 162,000,000 | 80,374,166 | 325,113,501 |
| *សមតុល្យនៅធនាគារផ្សេងៗ* | | | | |
| គណនីចរន្ត | 3,162,762 | 12,809,186 | 2,423,380 | 9,802,572 |
| គណនីសន្សំ | 129,127 | 522,964 | 63,518 | 256,930 |
| | 320,292,104 | 1,297,183,020 | 350,846,193 | 1,419,172,849 |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022

## 7. សមតុល្យនៅធនាគារជាតិនៃកម្ពុជា

| | កំណត់សម្គាល់ | ថ្ងៃទី31 ខែមីនា ឆ្នាំ2022 ដុល្លារអាមេរិក | ថ្ងៃទី31 ខែមីនា ឆ្នាំ2022 សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ដុល្លារអាមេរិក | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
|---|---|---|---|---|---|
| គណនីចរន្ត | (ក) | 103,706,447 | 420,011,110 | 139,856,737 | 569,776,347 |
| ប្រាក់បញ្ញើមានកាលកំណត់ (កាលវសានដំបូងរហូតដល់ 3ខែ) | (ក) | 40,000,000 | 162,000,000 | 373,638 | 1,522,201 |
| ប្រាក់បញ្ញើមានកាលកំណត់ (កាលវសានដំបូងច្រើនជាង 3ខែ) | (ក) | 671,605 | 2,720,000 | 148,184 | 603,702 |
| ប្រាក់តម្កល់ធានាលើដើមទុន | (ខ) | 30,000,000 | 121,500,000 | 30,000,000 | 122,220,000 |
| ប្រាក់បម្រុងកាតព្វកិច្ច | (គ) | 208,673,935 | 845,129,437 | 198,040,807 | 806,818,247 |
| | | 383,051,987 | 1,551,360,547 | 368,419,366 | 1,500,940,497 |

### (ក) គណនីចរន្ត និងប្រាក់បញ្ញើមានកាលកំណត់

គណនីចរន្តមិនទទួលបានការប្រាក់នោះទេ។

ក្នុងអំឡុងការិយបរិច្ឆេទ ប្រាក់បញ្ញើមានកាលកំណត់ដែលមានកាលវសានដំបូងរហូតដល់ 3ខែ ទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំចាប់ពី 0.31% ទៅ 1.63% (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ ចាប់ពី 0.04% ទៅ 1.63%) ហើយប្រាក់បញ្ញើមានកាលកំណត់ដែលមានកាលវសានដំបូងលើសពី 3ខែ ទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំចាប់ពី 0.68% ទៅ 1.98% (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ ចាប់ពី 0.13% ដល់ 1.91%) នៅក្នុងអំឡុងការិយបរិច្ឆេទ។

### (ខ) ប្រាក់តម្កល់ធានាលើដើមទុន

តាមប្រកាសលេខ ធ7-07-163 ចុះថ្ងៃទី13 ខែធ្នូ ឆ្នាំ2007 ស្តីអំពីការផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ក្រុមហ៊ុនតម្រូវឲ្យរក្សាប្រាក់តម្កល់ធានាលើដើមទុនស្មើនឹង 10% នៃដើមទុនចុះបញ្ជីជាមួយធនាគារជាតិនៃកម្ពុជា។ នៅថ្ងៃទី27 ខែមេសា ឆ្នាំ2022 ក្រុមហ៊ុនបានបង្កើនប្រាក់តម្កល់ធានាលើដើមទុនរហូតដល់ 40 លានដុល្លារអាមេរិក បន្ទាប់ពីទទួលបានការអនុម័តពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី25 ខែមេសា ឆ្នាំ2022 លើការបង្កើនដើមទុន។ ប្រាក់បញ្ញើនេះ មិនអាចយកមកសម្រាប់ជាការប្រើប្រាស់នៅក្នុងប្រតិបត្តិការរបស់ក្រុមហ៊ុននោះទេ ប៉ុន្តែត្រូវបានបង្វិលត្រឡប់មកវិញ នៅពេលក្រុមហ៊ុនស្ម័គ្រចិត្តបញ្ឈប់អាជីវកម្មនៅក្នុងប្រទេសកម្ពុជា។ ប្រាក់តម្កល់ធានាលើដើមទុន ទទួលបានការប្រាក់ប្រចាំឆ្នាំក្នុងអត្រា 0.04% (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ 0.04%) នៅក្នុងអំឡុងការិយបរិច្ឆេទ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ជំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022

## 7. សមតុល្យនៅធនាគារជាតិនៃកម្ពុជា (ត)

### (គ) ប្រាក់បម្រុងកាតព្វកិច្ច

ប្រាក់បម្រុងកាតព្វកិច្ច គឺជាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា ដែលត្រូវបានគណនាតាមអត្រា 8.00% នៃប្រាក់បញ្ញើរបស់អតិថិជន ដោយអនុលោមទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ7-07-163។ ប្រាក់បម្រុងកាតព្វកិច្ច នឹងត្រូវប្រែប្រួលទៅតាមកម្រិតនៃការដាក់ប្រាក់បញ្ញើពីអតិថិជន ហើយប្រាក់បម្រុងកាតព្វកិច្ចពុំទទួលបានការប្រាក់នោះទេ។

នៅថ្ងៃទី6 ខែមេសា ឆ្នាំ2022 ក្រុមហ៊ុនបានផ្ទេរទឹកប្រាក់បន្ថែមសរុបចំនួន 5,234,000 ដុល្លារអាមេរិក ទៅក្នុងគណនីបម្រុងកាតព្វកិច្ចជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីរក្សានូវកម្រិតប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា ដើម្បីឲ្យស្របតាមប្រកាសខាងលើ។

## 8. សមតុល្យនៅធនាគារផ្សេងៗ

| | ថ្ងៃទី31 ខែមីនា ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| គណនីចរន្ត | 3,162,762 | 12,809,186 | 2,240,993 | 9,129,805 |
| គណនីសន្សំ | 129,127 | 522,964 | 90,418 | 368,363 |
| សមតុល្យដុលជាមួយ ធនាគារផ្សេងៗ | 3,291,889 | 13,332,150 | 2,331,411 | 9,498,168 |
| សំវិធានធនលើការខាតបង់នៃ ឱនភាពនៃតម្លៃ | (32,920) | (133,326) | (23,314) | (94,981) |
| | 3,258,969 | 13,198,824 | 2,308,097 | 9,403,187 |

គណនីចរន្ត ទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំប្រាក់រហូតដល់ 0.75% (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ 0.00% ទៅ 0.75%) ហើយគណនីសន្សំទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំចាប់ពី 0.00% ទៅ 0.20% (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ 0.00% ទៅ 0.20%) ក្នុងអំឡុងការិយបរិច្ឆេទ។

## 9. ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជន ត្រូវបានចាត់ថ្នាក់ដូចខាងក្រោម៖

| | ថ្ងៃទី31 ខែមីនា ឆ្នាំ2022 | | | | |
|---|---|---|---|---|---|
| | ដំណាក់កាលទី 1 | ដំណាក់កាលទី 2 | ដំណាក់កាលទី 3 | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| ឥណទានបុគ្គល | 3,565,430,603 | 323,910,693 | 48,698,700 | 3,938,039,996 | 15,949,061,983 |
| ឥណទានសម្រាប់សហគ្រាសធុនតូច និងមធ្យម | 55,216,656 | 8,096,439 | 1,140,221 | 64,453,316 | 261,035,930 |
| ឥណទានបុគ្គលិក | 6,924,909 | 3,219 | 18,655 | 6,946,783 | 28,134,471 |
| ឥណទានក្រុម | 103,858 | 14,662 | 21,593 | 140,113 | 567,458 |
| | **3,627,676,026** | **332,025,013** | **49,879,169** | **4,009,580,208** | **16,238,799,842** |
| កម្រៃសេវាឥណទានដែលមិនទាន់រំលស់ | (34,077,940) | (2,851,739) | (327,904) | (37,257,583) | (150,893,211) |
| | **3,593,598,086** | **329,173,274** | **49,551,265** | **3,972,322,625** | **16,087,906,631** |
| ការប្រាក់បង្គរ | 26,673,188 | 2,880,909 | 2,435,224 | 31,989,321 | 129,556,750 |
| | **3,620,271,274** | **332,054,183** | **51,986,489** | **4,004,311,946** | **16,217,463,381** |
| សំវិធានធនលើការខាតបង់នៃឱនភាពនៃតម្លៃ | (9,365,320) | (17,301,063) | (29,108,085) | (55,774,468) | (225,886,595) |
| | **3,610,905,954** | **314,753,120** | **22,878,404** | **3,948,537,478** | **15,991,576,786** |

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | | | | |
|---|---|---|---|---|---|
| | ដំណាក់កាលទី 1 | ដំណាក់កាលទី 2 | ដំណាក់កាលទី 3 | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| ឥណទានបុគ្គល | 3,265,091,152 | 368,902,868 | 49,638,494 | 3,683,632,514 | 15,007,118,862 |
| ឥណទានសម្រាប់សហគ្រាសធុនតូច និងមធ្យម | 52,000,845 | 8,839,399 | 1,060,910 | 61,901,154 | 252,185,301 |
| ឥណទានបុគ្គលិក | 7,278,823 | 3,420 | 18,655 | 7,300,898 | 29,743,858 |
| ឥណទានក្រុម | 135,996 | 18,863 | 22,067 | 176,926 | 720,797 |
| | **3,324,506,816** | **377,764,550** | **50,740,126** | **3,753,011,492** | **15,289,768,818** |
| កម្រៃសេវាឥណទានដែលមិនទាន់រំលស់ | (31,195,926) | (3,300,001) | (344,684) | (34,840,611) | (141,940,649) |
| | **3,293,310,890** | **374,464,549** | **50,395,442** | **3,718,170,881** | **15,147,828,169** |
| ការប្រាក់បង្គរ | 24,831,162 | 3,238,478 | 2,117,904 | 30,187,544 | 122,984,054 |
| | **3,318,142,052** | **377,703,027** | **52,513,346** | **3,748,358,425** | **15,270,812,223** |
| សំវិធានធនលើការខាតបង់នៃឱនភាពនៃតម្លៃ | (8,693,888) | (18,871,562) | (29,224,982) | (56,790,432) | (231,364,220) |
| | **3,309,448,164** | **358,831,465** | **23,288,364** | **3,691,567,993** | **15,039,448,003** |

## 9. ឥណទានផ្តល់ដល់អតិថិជន (ត)

ក្នុងអំឡុងការិយបរិច្ឆេទ ក្រុមហ៊ុនបានទទួលស្គាល់សំវិធានធនលើការខាតបង់នៃឱនភាពនៃតម្លៃ លើឥណទានផ្តល់ដល់អតិថិជន សមតុល្យនៅធនាគារផ្សេងៗ និងទ្រព្យសកម្មផ្សេងៗ ដូចខាងក្រោម៖

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ3ខែដែលបានបញ្ចប់ថ្ងៃទី31 ខែមីនាឆ្នាំ2022 | | សម្រាប់ដំណាច់ការិយបរិច្ឆេទ3ខែដែលបានបញ្ចប់ថ្ងៃទី31 ខែមីនាឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| ឥណទានផ្តល់ដល់អតិថិជន | (1,015,964) | (4,127,862) | 4,267,256 | 17,320,794 |
| សមតុល្យនៅធនាគារផ្សេងៗ | 9,606 | 39,029 | (15,282) | (62,029) |
| ទ្រព្យសកម្មផ្សេងៗ | 407 | 1,654 | 344 | 1,394 |
| | (1,005,951) | (4,087,179) | 4,252,318 | 17,260,159 |

បម្រែបម្រួលសំវិធានធន លើការខាតបង់នៃឱនភាពនៃតម្លៃលើឥណទានផ្តល់ដល់អតិថិជន ក្នុងអំឡុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ3ខែដែលបានបញ្ចប់ថ្ងៃទី31 ខែមីនាឆ្នាំ2022 | | សម្រាប់ដំណាច់ការិយបរិច្ឆេទ3ខែដែលបានបញ្ចប់ថ្ងៃទី31 ខែមីនាឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| សមតុល្យនាដើមការិយបរិច្ឆេទ | 56,790,432 | 231,364,220 | 49,613,493 | 200,686,579 |
| សំវិធានធនលើការខាតបង់នៃឱនភាពនៃតម្លៃក្នុងអំឡុងការិយបរិច្ឆេទ | (1,015,964) | (4,127,862) | 4,267,256 | 17,320,794 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (1,349,763) | - | (59,744) |
| សមតុល្យនាចុងការិយបរិច្ឆេទ | 55,774,468 | 225,886,595 | 53,880,749 | 217,947,629 |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022

## 9. ឥណទានផ្តល់ដល់អតិថិជន (ត)

ការវិភាគបន្ថែមនៃឥណទានផ្តល់ដល់អតិថិជន ត្រូវបានបង្ហាញដូចខាងក្រោម៖

(ក) តាមទ្រព្យធានា

| | ថ្ងៃទី31 ខែមីនា ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| *មានវត្ថុបញ្ចាំ* | | | | |
| អចលនទ្រព្យ (ប្លង់រឹង) | 1,780,012,117 | 7,209,049,074 | 1,649,002,901 | 6,718,037,818 |
| ចលនវត្ថុ | 138,003 | 558,912 | 189,467 | 771,887 |
| ប្រាក់តម្កល់ទុក | 2,037,685 | 8,252,624 | 2,530,818 | 10,310,554 |
| ផ្សេងៗ | 635,505 | 2,573,795 | 640,271 | 2,608,465 |
| *ពុំមានវត្ថុបញ្ចាំ (*)* | | | | |
| អចលនទ្រព្យ (ប្លង់ទន់) | 2,220,140,776 | 8,991,570,143 | 2,094,535,205 | 8,533,136,427 |
| ចលនវត្ថុ | 391,294 | 1,584,741 | 363,670 | 1,481,591 |
| ផ្សេងៗ | 956,566 | 3,874,092 | 1,096,093 | 4,465,481 |
| | 4,004,311,946 | 16,217,463,381 | 3,748,358,425 | 15,270,812,223 |

(*) សំដៅទៅលើកម្ចីដែលវត្ថុបញ្ចាំ រួមមានប្លង់ទន់ និងពុំមានវត្ថុបញ្ចាំ ដែលអ្នកគ្រប់គ្រងជឿថាមានហានិភ័យខ្ពស់ ហើយចាត់ទុកជាកម្ចីពុំមានវត្ថុបញ្ចាំ។

(ខ) តាមនិវាសនភាព ទំនាក់ទំនងរូបិយប័ណ្ណ និងតាមវិស័យនានា

| | ថ្ងៃទី31 ខែមីនា ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| ***និវាសនភាព*** | | | | |
| និវាសនជន | 4,004,311,946 | 16,217,463,381 | 3,748,358,425 | 15,270,812,223 |
| ***ទំនាក់ទំនង*** | | | | |
| អតិថិជនខាងក្រៅ | 3,997,364,746 | 16,189,327,221 | 3,741,058,685 | 15,241,073,082 |
| ឥណទានបុគ្គលិក | 6,947,200 | 28,136,160 | 7,299,740 | 29,739,141 |
| | 4,004,311,946 | 16,217,463,381 | 3,748,358,425 | 15,270,812,223 |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ជំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2022

## 9. ឥណទានផ្តល់ដល់អតិថិជន (ត)

(ខ) តាមនិវាសនភាព ទំនាក់ទំនងរូបិយប័ណ្ណ និងតាមវិស័យនានា (ត)

| | ថ្ងៃទី31 ខែមីនា ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| ***រូបិយប័ណ្ណ*** | | | | |
| ដុល្លារអាមេរិក | 3,503,321,552 | 14,188,452,285 | 3,286,440,759 | 13,388,959,652 |
| រៀលខ្មែរ | 493,819,761 | 1,999,970,032 | 452,563,732 | 1,843,744,644 |
| បាតថៃ | 7,170,633 | 29,041,064 | 9,353,934 | 38,107,927 |
| | 4,004,311,946 | 16,217,463,381 | 3,748,358,425 | 15,270,812,223 |
| ***វិស័យ*** | | | | |
| ពាណិជ្ជកម្ម និងជំនួញ | 1,073,757,525 | 4,348,717,976 | 1,006,083,731 | 4,098,785,121 |
| សេវាកម្ម | 684,767,411 | 2,773,308,015 | 650,895,034 | 2,651,746,369 |
| អចលនទ្រព្យ | 591,702,356 | 2,396,394,541 | 536,199,895 | 2,184,478,372 |
| កសិកម្ម | 467,745,604 | 1,894,369,696 | 445,927,277 | 1,816,707,726 |
| កែលម្អគេហដ្ឋាន | 501,458,577 | 2,030,907,237 | 453,670,525 | 1,848,253,719 |
| យានយន្ត | 313,626,098 | 1,270,185,697 | 299,573,327 | 1,220,461,734 |
| ការដឹកជញ្ជូន | 257,992,567 | 1,044,869,896 | 249,173,560 | 1,015,133,083 |
| ផលិតកម្ម | 46,647,212 | 188,921,209 | 45,502,628 | 185,377,706 |
